YUNNAN DAILY PRESS GROUP
No.169

ប្រទេសចិន-ខេត្តយូនណាន

ស្មើតម្លៃ ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី27 លេខ7867 ថ្ងៃសុក្រ ទី22 ខែកុម្ភ: ឆ្នាំ2019

ខេត្តយូណានសម្រេចការអភិវឌ្ឍន៍ដែលមានគុណភាព ខ្ពស់ផ្តល់ផលប្រយោជន៍ជាក់ស្តែងដល់ប្រជាជន

ព្រឹកថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៩ កិច្ចប្រជុំលើកទី ២នៃសភាតំណាងប្រជាជន ខេត្តយូនណាន នីតិកាលទី១៣បានបើកសម័យប្រជុំជាផ្លូវការ នៅសាលប្រជុំ ហៃកឺង នៃខេត្តយូណាន

តាមប្រភពព័ត៌មានពីកិច្ចប្រជុំលើកទី ២ នៃសភាតំណាងប្រជាជន ខេត្តយូណាននីតិកាលទី ១៣ បានឱ្យដឹងថា សាលារដ្ឋបាលខេត្តយូនណានបានសម្រេចដោយជោគជ័យនូវការងារសំខាន់ចំនួន ១០ នៅឆ្នាំ ២០១៨ សម្រាប់ផ្តល់ផលប្រយោជន៍ដល់ប្រជាជន ។ នៅឆ្នាំ ២០១៩ នេះសាលារដ្ឋបាលខេត្តយូនណាននឹងបន្តធ្វើការងារសំខាន់ចំនួន១០ទៀតដើម្បីលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជន ។

១-កសាងទីរួមស្រុកដ៏ស្រស់ស្អាតនិងកូនឃុំពិសេស។ ចាប់ដំណើរការអនុវត្តគម្រោងអំពីការកសាងទីរួមស្រុកដ៏ស្រស់ស្អាតជ្រើសរើសទីរួមស្រុកស្រស់ស្អាតចំនួន ២០ និងកូនឃុំពិសេសជាគំរូចំនួន ១៥ ។

២-អនុវត្តន៍គម្រោងអភិរក្សវប្បធម៌ជនជាតិភាគតិច និងគម្រោង "មួយរយ"ចំនួន២ ។ អនុវត្តន៍គម្រោងអភិរក្សវប្បធម៌ប្រពៃណីនៃជនជាតិភាគតិចចំនួន១៥០ជនជាតិ និងបង្កើតស្នាដៃវប្បធម៌ប្រណីតរបស់ជនជាតិភាគិតចំនួន ២០ ។

៣-ជំរុញការបណ្តុះបណ្តាលពលករនៅក្នុងតំបន់ជនបទផ្តល់ការគាំទ្រដល់ការបង្កើតមុខជំនួញ ដើម្បីផ្តល់ឱកាសការងារកាន់តែច្រើន ។ បណ្តុះបណ្តាលប្រជាកសិករ៣ពាលាន នាក់ និងផ្តល់ការគាំទ្រដល់អ្នកបង្កើតមុខជំនួញជាង៨ម៉ឺននាក់ ។

៤-អនុវត្តន៍វិស្វកម្មថែរក្សាសុខភាពប្រជាជនដើម្បីបង្កើនសុខភាពរបស់ប្រជាជនគ្រប់ៗគ្នា ។

៥-អនុវត្តន៍សកម្មភាពអំពីការលើកកម្ពស់សមត្ថភាពសេវាកម្មនៃស្ថាប័នសុខាភិបាលមូលដ្ឋាន ។ ពង្រឹងសមត្ថភាពសុខាភិបាលនៃមន្ទីរពេទ្យថ្នាក់ស្រុកចំនួន៤០ឱ្យស្របតាមស្តង់ដារធានាឱ្យមជ្ឈមណ្ឌលសុខាភាព នៃឃុំ និងសហគមន៍ចំនួន៤០០មានសម្ភារៈបរិក្ខារពេទ្យស្របតាមស្តង់ដារ ។

៦-អនុវត្តន៍វិស្វកម្មហាត់ប្រាណ ខេត្តយូណានដ៏ចម្រុះពណ៌អនុវត្តន៍គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធកីឡាថ្នាក់ស្រុក ឃុំ និងភូមិ ។

៧-អនុវត្តន៍សកម្មភាពពិសេសសម្រាប់លើកកម្ពស់គុណភាពនៃការថែរក្សាមនុស្សចាស់សាងសង់ជាថ្មី និងជួសជុលមជ្ឈមណ្ឌលថែរក្សាមនុស្សចាស់មួយចំនួន ។

៨-ជំរុញការធ្វើ"បដិវត្តន៍បន្ទប់ទឹក" ។ សាងសង់ជាថ្មី និងជួសជុលបន្ទប់ទឹកសាធារណៈចំនួនជាង ១.០០០ក្នុងទីក្រុងជួសជុលបន្ទប់ទឹកសាធារណៈចំនួន១.៦០០នៅទីរួមឃុំ។

៩-សម្រេចបានការបំពេញបែបបទរដ្ឋបាលតាមទូរស័ព្ទ។អនុវត្តន៍គម្រោងនៃការបំពេញបែបបទនៃកិច្ចការប្រចាំថ្ងៃផ្សេងៗតាមទូរស័ព្ទសម្រេចបានការបំពេញបែបបទនៃកិច្ចការ៥០០ប្រការសម្រាប់ប្រជាជន ក្នុងឆ្នាំ២០១៩ ។

១០-អនុវត្តន៍វិស្វកម្មផ្តល់ផលប្រយោជន៍ដល់ប្រជាជនលើវិស័យសេវាកម្មច្បាប់សាធារណៈ។បញ្ចប់ការសាងសង់ស្ថានីយផ្តល់សេវាកម្មច្បាប់ សាធារណៈមួយចំនួននៅឃុំនិងសហគមន៍(ភូមិ)ដែលស្រប តាមស្តង់ដារ។ ធានាឱ្យភូមិក្រីក្រទាំងអស់មានទីប្រឹក្សាផ្នែកច្បាប់។ **ដោយចាំងយីន និងឈូជូនីង**

(សូមទស្សនាវេបសាយ "ស្ពានយូនណាន" ដើម្បីស្វែងរកព័ត៌មានអំពីកិច្ច ប្រជុំសភាតំណាងប្រជាជន និងសភាប្រឹក្សានយោបាយប្រជាជន នៃខេត្តយូណាន)

ខ្សែរថភ្លើងចិន-ឡាវ ផ្តល់ផល-ប្រយោជន៍ដល់ប្រជាជនក្នុងតំបន់

ពេលថ្មីៗនេះ ស្ពានធំណាន-ខឺណៃដែលជាផ្នែកសំខាន់មួយនៃខ្សែរថភ្លើងចិន-ឡាវ បានចាប់ដំណើរការសាងសង់ជាផ្លូវការ ។ ស្ពានដ៏ធំនេះនឹងអាចផ្តល់ផលប្រយោជន៍ជាក់ស្តែងដល់ប្រជាជនឡាវ ។ លោក លី ពីងអគ្គនាយកនៃក្រុមហ៊ុនសាងសង់ខ្សែរថភ្លើងចិន-ឡាវ បានប្រាប់អ្នកកាសែតថា នៅឆ្នាំ ២០១៩ នេះ ក្រុមហ៊ុននឹងបញ្ចប់ការសាងសង់ស្ពាន និងផ្លូវដែកអ្ជងភ្នំតាមខ្សែរថភ្លើងចិន-ឡាវ(គម្រោងដេញថ្ងៃជាស្រេច)ចំនួនជាង ៩០ ភាគរយ ។

ខ្សែរថភ្លើងចិន-ឡាវ ជាខ្សែរថភ្លើងអន្តរជាតិទី១ ដែលភាគីចិនចូលរួមជាអ្នកសាងសង់សំខាន់ និងតភ្ជាប់នឹងបណ្តាញខ្សែរថភ្លើងចិនក្រោយពីគំនិតផ្តួចផ្តើម"ខ្សែក្រវាត់មួយ និងផ្លូវមួយ"ត្រូវបានលើក ឡើងរៀងមក ។ លោក ស៊ីសាយធី អ៊ែ-អាវិន ប្រធានមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវអំពីប្រទេសចិននៃសាកលវិទ្យាល័យរដ្ឋប្រទេសឡាវបានបញ្ជាក់ថា រឃ្យែងសេដ្ឋកិច្ចចិន-ឡាវ និងខ្សែរថភ្លើងចិន-ឡាវត្រូវបង្កើតឡើងដោយព្រមជាមួយគ្នាដែលនឹងអាចផ្តល់ផលប្រយោជន៍ជាក់ស្តែងដល់ប្រជាជនឡាវនិងមានសារសំខាន់ណាស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឡាវនិងការជំរុញការកសាងសហគមន៍រួមវាសនាចិន-ឡាវ ។

សព្វថ្ងៃ គម្រោងសាងសង់ខ្សែរថភ្លើងចិន-ឡាវ បានជំរុញការអភិវឌ្ឍនៃវិស័យសម្ភារសំណង់ថាមពលអគ្គិសនី កសិកម្ម ការចិញ្ចឹមសត្វ សេវាកម្ម និងប្រព័ន្ធឡូជីស្ទីកក្នុងប្រទេសឡាវ ។

តាមស្ថិតិដែលមានលក្ខណៈមិនពេញលេញគម្រោងនេះបានផ្តល់ការងារដល់កម្មករឡាវជាង ៣២.០០០ នាក់ ក្នុងនោះ មានជាង ៤.៣០០នាក់ កំពុងធ្វើការដើម្បីអនុវត្តន៍ការសាងសង់ខ្សែរថភ្លើងនេះ ។ គម្រោងនេះបានផ្តល់ឱកាសការងារដ៏ច្រើនដល់ប្រជាជនឡាវដែលរស់នៅក្នុងតំបន់ជុំវិញ ។ ក្រៅពីនេះក្នុងអំឡុងពេលសាងសង់ខ្សែរថភ្លើងនេះ ក្រុមហ៊ុននឹងសាងសង់និងជួសជុលផ្លូវថ្នល់ដែលមានប្រវែងសរុប១.១០០គីឡូម៉ែត្រជួសជុលផ្ទះចាស់ដែលមានទំហំ ២៧.១០០ម៉ឺនម៉ែត្រការ៉ែ និងផ្តល់ជំនួយឧបត្ថម្ភដែលមានតម្លៃជាង ៨ សែននាក់ដល់សិស្សនិស្សិតឡាវ ។

គម្រោងសាងសង់ខ្សែរថភ្លើងចិន-ឡាវ បានផ្តល់ឱកាសពាណិជ្ជកម្មដ៏ច្រើនដល់អ្នកភូមិ ដែលរស់នៅក្នុងភូមិណៃសាយដែលមានទីតាំងស្ថិតនៅក្បែរស្ថានីយរថភ្លើងខាងជើងក្រុងវៀងចន្ទន៍ ។ លោក ស៊ូផាត់ មេភូមិណៃសាយបានប្រាប់អ្នកកាសែតដោយមានភាពសប្បាយរីយរាយថា សព្វថ្ងៃអ្នកភូមិអាចទទួលបានចំណូលកាន់តែច្រើន ហើយមានអ្នកវិនិយោគមកបង្កើតរោងចក្រដែលបានធ្វើឱ្យអ្នកភូមិមានជីវភាពរស់នៅកាន់តែល្អប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ។

ដោយ សុន ក្វាងយុំង

អបអរសាទរខួបលើកទី៧០នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន

មុននឹងចូលឆ្នាំ ប្រពៃណីចិនអតិថិជនដ៏ច្រើនកុះករ មកទិញទំនិញនៅផ្សារលក់ផ្លែឈើ និងអាហារ ក្រុងយីអ្វី ខេត្តជឺជាំង ។
ដោយ កុង សៀនមៃង (កាសែតប្រជាជន ដេលី)

ឆ្នាំ ២០១៩ ជាខួបលើកទី ៧០ នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន ហើយក៏ជាឆ្នាំគន្លឹះ នៃការកសាងសង្គមធូរធារគ្រប់ជ្រុងជ្រោយដោយជោគជ័យ ។ ក្នុងរយៈពេល៧០ ឆ្នាំកន្លងទៅនោះ ប្រទេសចិនបានប្រែក្លាយពីប្រទេស ក្រីក្រមួយទៅជាសេដ្ឋកិច្ចធំទី ២ លើ ពិភពលោក ដែលបានទទួលនូវសមិទ្ធផលច្រើនគួរឱ្យកត់សម្គាល់ក្នុង ការពង្រឹងសមត្ថភាពចម្រុះនៃប្រទេសជាតិ ។ ទស្សនាវដ្តីយើងខ្ញុំនឹងបង្កើត "ផ្នែកអបអរសាទរខួបលើកទី ៧០ នៃការបង្កើតសាធារណរដ្ឋប្រជាមានិត ចិន" ដើម្បីបង្ហាញជូនលោកអ្នកអំពីការរីកចម្រើននៃប្រទេសចិនថ្មីក្នុង រយៈពេល ៧០ ឆ្នាំកន្លងទៅ ។

ក្រោយពីប្រទេសចិនថ្មីត្រូវ បានបង្កើតឡើងរៀងមកការរស់នៅរបស់ប្រជាជនចិនបានកើតមានការ ផ្លាស់ប្តូរគួរឱ្យកត់សម្គាល់។ ប្រជាជនចិនបានទទួលនូវចំណូលកាន់តែ ច្រើន ហើយកាន់តែមានភាពធូរធារក្នុងការរស់នៅប្រចាំថ្ងៃ ។ សន្ទស្សន៍ Engel's Coefficient បានធ្លាក់ចុះពី ៦៣,៩ភាគរយ នៅឆ្នាំ ១៩៧៨ ដល់ ២៩,៣ភាគរយ នៅឆ្នាំ ២០១៧ ចំណែករចនាសម្ព័ន្ធ និងកម្រិតនៃ ការចំណាយប្រាក់របស់ប្រជាជនចិន ក៏បានត្រូវកែលម្អជាច្រើនផងដែរ ។

បាយយប់ដាច់ឆ្នាំ:រសជាតិឆ្នាំថ្មីដែលប្រកបដោយសុភមង្គល

បាយយប់ដាច់ឆ្នាំ គឺជាបាយមួយពេលដែលមានសារសំខាន់ជាងគេសម្រាប់ជនជាតិចិនគ្រប់ៗគ្នាហើយក៏ជាផ្នែកដ៏សំខាន់នៃពិធីអបអរសាទរបុណ្យចូលឆ្នាំប្រពៃណីចិនដែរ។ វាបានបង្កប់ដោយមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅរបស់ជនជាតិចិនចំពោះគ្រួសាររបស់ខ្លួន។ក្នុងរយៈពេល ៤០ឆ្នាំក្រោយពីបានអនុវត្តន៍គោលនយោបាយកែទម្រង់ និងបើកចំហរៀងមកប្រទេសចិនបានទទួលការរីកចម្រើនច្រើនក្នុងវិស័យ សេដ្ឋកិច្ច និងសង្គមកិច្ច។ បាយយប់ដាច់ឆ្នាំមិនត្រឹមតែជាបាយមួយពេលដែលមានម្ហូបឆ្ងាញ់ៗប៉ុណ្ណោះទេហើយក៏បានតំណាងឱ្យមនោសញ្ចេតនាចំពោះក្រុមគ្រួសាររបស់ ជនជាតិចិនផងដែរ ។

បាយយប់ដាច់ឆ្នាំមានប្រភពដើមពីសម័យបុរេប្រវត្តិសាស្ត្រ ។ តាមតំណាលតៗគ្នាថា កាលពីដើមមានសត្វសាហាវមួយក្បាល ឈ្មោះ "នីន"(ឆ្នាំ) ។ នៅថ្ងៃខួបកំណើតរបស់វាអ្នកស្រុកគ្រប់គ្រួសារតែង តែជួបជុំជាមួយគ្នារៀបចំពិធីសែនអ្នកតានិងអុជផាវដើម្បីបណ្តេញសត្វ"នីន" នេះ រួចបិទទ្វារនិងបង្អួចហើយហូបបាយយប់ដាច់ឆ្នាំ នេះក៏ហៅថា "ឆ្លងបុណ្យចូលឆ្នាំប្រពៃណីចិន"(ឆ្លង"នីន")។ យូរៗទៅ ទម្លាប់នេះបានក្លាយទៅជាពិធីអបអរសាទរដ៏សំខាន់របស់ជនជាតិចិន ។ ពិតមែនតែជនជាតិចិនបានបោះបង់ចោលនូវជំនឿអរូបីអំពីសត្វ"នីន"នេះ ក៏ប៉ុន្តែទម្លាប់ហូបបាយយប់ដាច់ឆ្នាំបានត្រូវរក្សាទុកនិងទទួលបន្តពីមួយជំនាន់ទៅមួយជំនាន់រហូតដល់បច្ចុប្បន្ននេះ ។

ដោយសារប្រទេសចិនមានទំហំធំ ហើយប្រជាជនចិននៅតំបន់ផ្សេងៗមានទម្លាប់ហូបចុកខុសពីគ្នាដូច្នេះ ម្ហូបដែលជនជាតិចិនហូបនៅយប់ដាច់ឆ្នាំនោះក៏មានលក្ខណៈផ្សេងពីគ្នាដែរ ។ ជនជាតិចិននៅភាគខាងជើងចូលចិត្តហូបនំគាវ ឯចំណែកជនជាតិចិននៅភាគខាងត្បូងចូលចិត្តហូបនំ"នីនការ" ។ ទោះជាហូបអ្វីនៅបុណ្យចូលឆ្នាំប្រពៃណីចិនក៏ដោយ ក៏ប៉ុន្តែមានគោលការណ៍រួមមួយគឺបាយយប់ដាច់ឆ្នាំត្រូវតំណាងឱ្យសំណាងល្អ និងសម្តែងនូវក្តីជូនពរដ៏ល្អបវរចំពោះឆ្នាំថ្មី ។

បាយយប់ដាច់ឆ្នាំ បានបង្ហាញឱ្យឃើញពីការគោរព និងការរាប់អានគ្នារវាងសមាជិកផ្សេងៗក្នុងគ្រួសាររបស់ជនជាតិចិន ។ មនោសញ្ចេតនានេះបានធ្វើឱ្យគ្រួសារជនជាតិចិនមានទំនាក់ទំនងកាន់តែស្និទ្ធស្នាល ។

បាយយប់ដាច់ឆ្នាំ:រសជាតិឆ្នាំថ្មីដែលប្រកបដោយសុភមង្គល